ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០៣ សរ

# សារាចរ
# ស្តីពី
# ការដាក់មន្រ្តីរាជការស៊ីវិលទាំងពីរភេទអោយចូលនិវត្តន៍

ផ្អែកតាមខ្លឹមសារនៃព្រះរាជក្រមលេខ ០៦ នស ៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ក្រសួង ស្ថាប័នមួយចំនួន ត្រូវកសាងលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌនីមួយៗ។ រាជរដ្ឋាភិបាលបានប្រកាសផ្សាយរួចហើយនូវព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមួយចំនួន ឯលក្ខន្តិកៈដោយឡែកមួយចំនួនទៀត កំពុងតែកសាងឡើងជាបន្តបន្ទាប់។ ក្នុងស្ថានភាពដែលយើងពុំទាន់បានធ្វើសមាហរណកម្មក្របខ័ណ្ឌបច្ចុប្បន្នផ្ទេរចូលទៅក្នុងក្របខ័ណ្ឌថ្មីនៃលក្ខន្តិកៈដោយឡែកនោះ ក្រសួង ស្ថាប័ននីមួយៗ ជួបការលំបាកក្នុងការរៀបចំដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍។ ដូចនេះដើម្បីឱ្យស្របនឹងស្ថានភាពជាក់ស្តែង រាជរដ្ឋាភិបាលសូមធ្វើការកំណត់ល័ក្ខខ័ណ្ឌនៃការចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលដូចតទៅ៖

**១-មន្ត្រីដែលដល់អាយុ ៦០ ឆ្នាំ ត្រូវចូលនិវត្តន៍:**

ក- មន្ត្រីដែលកំពុងកាន់មុខតំណែងពិតប្រាកដក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន មានៈ

- អគ្គនាយក អគ្គលេខាធិការ អគ្គាធិការ អភិបាលខេត្ត ក្រុង
- អគ្គនាយករង អគ្គលេខាធិការរង អគ្គាធិការរង ប្រធាននាយកដ្ឋាន អភិបាលរងខេត្ត ក្រុង
- អនុប្រធាននាយកដ្ឋាន អធិការរង ប្រធានមន្ទីរខេត្ត ក្រុង អភិបាលស្រុក ខ័ណ្ឌ
- និងមុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន។

ខ- មន្ត្រីកំពុងបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋ ដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្នចាប់ពី ក II-៧ ឡើងទៅ។

គ- មន្ត្រីដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ខ I ឬមន្ត្រីដែលមានសញ្ញាប័ត្រសមមូលនឹងបរិញ្ញាប័ត្រឡើងទៅ។

ឃ-មន្ត្រីដែលបម្រើការងារក្នុងក្របខ័ណ្ឌគ្រូបង្រៀនរបស់ក្រសួងអប់រំ យុវជន និងកីឡាទាំងអស់ និងគ្រូបង្រៀនអចិន្ត្រៃយ៍នៅតាមសាកលវិទ្យាល័យ មហាវិទ្យាល័យ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងនានា ហើយដែលបានទទួលប្រាក់កំរៃគរុកោសល្យ។

**២-មន្ត្រីដែលដល់អាយុ ៥៨ ឆ្នាំ ត្រូវចូលនិវត្តន៍:**

ក- មន្ត្រីដែលកំពុងកាន់មុខតំណែងពិតប្រាកដក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន មាន:

- ប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល-អភិបាលរងស្រុក ខ័ណ្ឌ អនុប្រធានមន្ទីរនៅខេត្ត ក្រុង
- អនុប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល-ប្រធានការិយាល័យនៃមន្ទីរនៅខេត្ត ក្រុង
- អនុប្រធានការិយាល័យនៃមន្ទីរនៅខេត្ត ក្រុង
- និងមុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធនៃការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង ស្ថាប័ន

ខ- មន្ត្រីកំពុងបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋ ដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្នចាប់ពី ក II-១០ ដល់ ក II-៨។

គ- មន្ត្រីដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ខ II ឬមន្ត្រីដែលមានសញ្ញាប័ត្រសមមូលនឹងសញ្ញាប័ត្រមធ្យមសិក្សាឯកទេស

**៣-មន្ត្រីដែលដល់អាយុ ៥៥ ឆ្នាំ ត្រូវចូលនិវត្តន៍គឺ** :

មន្ត្រីដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ខ II-១១ ខ III- ខ IV- គ I- គ II- គ III និង គ IV។

**៤- ករណីមន្ត្រីដែលមានអាយុ ៥៥ឆ្នាំ ឡើងទៅ** ហើយកំពុងកាន់មុខតំណែង ឬមានលក្ខ័ខណ្ឌដូចចំនុច ១ និង ២ ខាងលើ តែមិនទាន់បានដាក់ឱ្យចូលនិវត្តន៍ ត្រូវនៅបន្តការងាររហូតដល់អាយុចូលនិវត្តន៍ គឺ ៦០ឆ្នាំ ឬ ៥៨ ឆ្នាំ។

បើមានការលំបាកស្មុគ្រស្មាញក្នុងការអនុវត្តន៍ គ្រប់ក្រសួង ស្ថាប័ន ត្រូវ ពិគ្រោះ យោបល់ ជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីពិនិត្យដោះស្រាយ។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តខ្លឹមសារខាងលើដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- លេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខេត្ត ក្រុង
- ឯកសារ–កាលប្បវត្តិ